# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ

ឆ្នាំគំរប់ ១៣

ភាគទី ១៤

ភ្នំពេញ

ការផ្សាយរបស់ព្រះរាជបណ្ណាល័យ

ព.ស. ២៤៨៤

គ.ស. ១៩៤១

ព្រះរាជបណ្ណាល័យកម្ពុជា

# KAMBUJASURIYÂ

# កម្ពុជសុរិយា

*ជាទស្សនាវដ្ដីចេញផ្សាយពីព្រះរាជបណ្ណាល័យ មួយខែពីរក្បាល*

ឆ្នាំគំរប់ ១៣

*ភាគទី ១៤*

គណៈរដ្ឋមន្ត្រីនឹងសម្តេចសង្ឃនាយកទាំងពីរគណៈ

បានអនុញ្ញាតហើយ

BIBLIOTHEQUE ROYALE DU CAMBODGE

*ភ្នំពេញ*

ការផ្សាយរបស់ព្រះរាជបណ្ណាល័យ

ព.ស. ២៤៨៤

គ.ស. ១៩៤១

# បញ្ជីរឿង


១ — អំពីយោបល់ខ្លះរបស់លោកស្រីកមក្រិស្ណៈ ជាមហាកវីនៃប្រទេសឥណ្ឌា . . . ៣

២ — អំពីរឿង ១ របស់លោកលុយសៀងលេវី-ព្រុហ្ល (និយាយអំពីគំនិតរបស់មនុស្ស សម័យដាន់ដើម) . . . . . . . . . . . . . . . . . . . . . . ៧

៣ — សេចក្ដីមួយនិយាយពីពង្សាវតារសង្ខេបរបស់ប្រទេសភូមា . . . . . . . . . . ១៣

៤ — អំពីកិច្ចការជាស្នាដៃរបស់ពុទ្ធសាសនបណ្ឌិត្យនៅប្រទេសខ្មែរ ប្រទេសលាវនឹងដែនកូសាំងស៊ីន (តមកនឹងចប់) . . . . . . . . . . . . . . . . . . . . ១៦

៥ — អំពីពង្សាវតារក្រិក ស្រង់យកអំពីគោលបារីកផ្សេងៗ ក្នុងពង្សាវតារលោក (តមក) ១៩

៦ — អតាមយកថា របស់ខេមររង្សី (តមកនឹងចប់) . . . . . . . . . . . . . ២២


## រូបក្រៅរឿង


ហ្លួងព្រះបាង (ប្រទេសលាវ)-ពិធីហែភូងីងី.ទាវត្តសៀងថង នៅឱកាសចូលឆ្នាំថ្មីនៃជនជាតិលាវ . . . . . . . . . . . . . . . . . . . . . . . . . ១

# TABLE DES MATIÈRES

Pages

1° Quelques idées de SHRIRAMAKRISNA, Grand penseur de l'Inde.. 3

2° Un article de Lucien Lévy-Bruhl (la pensée des primitifs).. 7

3° Quelques notes sur l'histoire ancienne de la Birmanie...... 13

4° L'Œuvre de l'Institut d'études bouddhiques au Cambodge, en Cochinchine et au Laos (suite et fin).................. 16

5° Histoire de la Grèce extrait de divers documents de l'histoire générale (suite)........................................ 19

6° ANĀMAYAKATHĀ par KHÉMARARANSĪ (suite et fin)........ .. 22

HORS TEXTE:

Luong-Prabang (Laos) la procession du «Phu ngeu ngeu» à l'occasion nouvel an laotien......................... 1



ហ្លួងព្រះបាង (ប្រទេសលាវ) — ពិធីហែភូតធំទៅវត្តសៀងថង នៅទិវាសចូលឆ្នាំថ្មីនៃជនជាតិលាវ ។

# អំពីយោបល់ខ្លះរបស់លោកស្រីរ៉ាមក្រិស្ណៈ ជាមហាកវីនៃឥណ្ឌៀសម័យថ្មី

មច្ឆរិយៈគឺសេចក្ដីកំណាញ់របស់បុរសបុគ្គល មិនដែលចេញផុតស្រឡះពីខ្លួនទេ ទុកជាព្យាយាមលះបង់ជាយូរអង្វែងយ៉ាងណា ក៏នៅតែមានស្នាមគំនូសឲ្យមើលឃើញជានិច្ច; ធម្មតាស្លឹកដូង (ធាងដូង) កាលធ្លាក់ចុះមកដី តែងមានស្នាមជាប់នៅនឹងដើម នេះមានទំនងដូចជាមច្ឆរិយៈដែរ ប៉ុន្តែមានតិចតួចស្ដួចស្ដើងចំពោះមនុស្សដែលមានឥស្សរចិត្ត ។

ប្រសិនបើអ្នកពាក់ស្បែកជើង អ្នកអាចនឹងដើរទៅបានយ៉ាងស្រួលលើបន្លានានា, ស្បែកជើងពោលគឺចំណេះវិជ្ជាដែលស្គាល់កិច្ចការសព្វសារពើនេះហើយដែលអ្នកអាចឈានជើងត្រាច់រង្គាត់ទៅក្នុងលោកដែលមានសុទ្ធតែបន្លាប្រូងប្រាងបានដោយស្រួលឥតគ្រោះថ្នាក់ ។

បណ្ដាត្រីដែលជាប់នៅក្នុងសំណាញ់ មានត្រីបំពួកខ្លះសម្ងំនៅយ៉ាងស្ងាត់ស្ងៀមក្នុងសំណាញ់ ត្រីបំពួកខ្លះខំបម្រះនទៀល ដើម្បីឲ្យរួចរបូតទៅតែមិនអាចរួចរបូតពីសំណាញ់នោះបាន, ឯត្រីបំពួកខ្លះទៀត ខំបម្រះនទៀលទាល់តែរហែកសំណាញ់នោះចេញទៅបាន ។ សេចក្ដីឧបមានេះ មានទំនងដូចមនុស្ស ៣ ពួកដែលមាននៅក្នុងលោកនេះ គឺមនុស្សពួក ១ ជាមនុស្សជាប់ចំណង, មនុស្សពួកមួយខំរកឧបាយដោះស្រាយចំណង; មាន ១ ពួកទៀតខំដោះខ្លួនទាល់តែរួចស្រឡះជាឥស្សរៈឡើងបាន ។

សត្វក្រពើមានស្បែកក្រាស់ជាអាវុធ ហើយគេមិនអាចប្រើអាវុធណាមួយចាក់ទៅលើស្បែកវានោះបានឡើយ នេះដូចជាអ្នកមានចិត្តមេត្តាខ្នាន ខាងផ្សាសនាដល់មនុស្សណាមួយដែលមាននិស្ស័យរឡេះរឡោះឲ្យបានល្អឡើង អំពីនេះទៅទឹងមិនមានហេតុកេខ្លីមួយតាំងនៅក្នុងចិត្តរបស់បុរសនោះឡើយ ។

មានទំជាក់ទួនច្រើនមើលពីខាងក្រៅដូចៗគ្នា តែគេអាចប្រែប្រួលលាយគ្នាដោយវត្ថុផ្សេងៗ ជាច្រើនយ៉ាង គឺជាទំបំពូកខ្លះដាក់ដូង ចំពូកខ្លះដាក់ទឹកដោះគោជាដើម រឿងនេះមានឧបមាដូចជាកាយរបស់មនុស្សយើង សឹងមានទ្រង់ទ្រាយដូចៗគ្នា តែដោយពិតនោះមនុស្សយើងសុទ្ធតែផ្សេងៗគ្នា ដោយលក្ខណៈនិងនិស្ស័យសន្តានចិត្ត

ហេតុនេះ ចូរប្រយ័ត្នខ្លួន:

១)- ប្រយ័ត្នមនុស្សដែលមានសំដីហូរដូចជាទឹក

២)- ប្រយ័ត្នមនុស្សដែលលាក់បាំងចិត្តគំនិតរបស់ខ្លួន

៣)- ប្រយ័ត្នមនុស្សដែលអួតពីធម៌អាចប្រកាសខ្លួនថាជាអ្នកមានមេត្តាចិត្ត

៤)- ប្រយ័ត្នស្ត្រីដែលមានក្ដោងវែង

៥)- ប្រយ័ត្នអណ្តូងទឹកដែលគ្របដោយស្មៅខៀវស្រស់ហើយមានទឹកត្រជាក់ តែជាទឹកឲ្យទោសដល់អ្នកបរិភោគ ។

ពួកស្ត្រីដែលនៅក្នុងប្រទេសឥណ្ឌាខាងជើងអាចទូលដើរទៅបាន ដោយមានក្អមទឹក ៤-៥ ត្រួតនៅលើក្បាលដាក់ត្រួតលើគ្នា ហើយនិយាយស្តីនឹងមិត្តភក្តិ ដំណាលពីសេចក្តីលំបាកនឹងសេចក្តីសប្បាយក៏បាន ដោយហេតុស្ត្រីអស់នោះមានគំនិតជាប់នៅនឹងក្អមទឹកអស់នោះជានិច្ចដើម្បីទប់ក្អមទឹកឲ្យនៅនឹងថ្កល់ មិនឲ្យក្រឡុកកំពប់ទឹកចេញបាន ។ ឯអ្នកដែលធ្វើដំណើរទៅកាន់ទីគោរពប្រតិបត្តិតាមផ្លូវធម៌ត្រូវតែប្រុងប្រយ័ត្នគ្រប់ៗឱកាស ឬគ្រប់ៗខណៈ កុំឲ្យចិត្តឃ្លាកឃ្លាតចេញពីផ្លូវធម៌ ។

ប្រសិនបើអ្នកយកប្រេងមកលាបដៃ ហើយសឹមចាប់ផ្លែខ្នុរដែលប្រឡាក់ជ័រ ឯជ័រខ្នុរមិនប្រឡាក់ជាប់ម្រាមដៃរបស់អ្នកឡើយ សេចក្តីនេះមានឧបមាយ៉ាងណា មានឧបមេយ្យដូចជាអ្នកលាបស្រឡាបខ្លួនឲ្យជោកដោយគុណធម៌ដ៏បរិសុទ្ធ ខ្លួនអ្នកនៅក្នុងលោកនេះបានដោយឥតព្រួយកង្វល់ដោយជាប់ចិត្តស្រឡាញ់មាសប្រាក់ ឬមានចិត្តភ្លើនទៅក្នុងផ្លូវតណ្ហាគតៈ ។

វាជាការលំបាកណាស់ ក្នុងការបម្រះឲ្យផុតស្រឡះចាកមច្ឆរិយៈគឺសេចក្តីកំណាញ់យល់តែប្រយោជន៍ខ្លួន កម្រកំចាត់ចេញបានណាស់ ដូចចានដែលគេបុកមើមខ្ទឹមសឬខ្ទឹមក្រហមដាក់ក្នុងចាននោះ ក្លិនខ្ទឹមនៅតែជាប់នៅជានិច្ច ទុកជាព្យាយាមលាងដល់ ១០០ ដងក៏មិនអស់ក្លិនខ្ទឹម ។

នេះមានទំនងដូចជាការគិតដល់ផលប្រយោជន៍របស់យើង កម្រយើងធ្វើការលះបេញបានជាបំផុត ។

អ្នកដែលប្រកាន់ថាខ្លួនជាអ្នកចេះដឹងច្រើន គេទុកជាមនុស្សល្ងង់ខ្លៅទៅវិញ ។ ក្អែកញីជាសត្វឈ្លាសវៃណាស់តាមចិត្តគំនិតរបស់វា តែបែរជាសត្វក្អែកញីនេះឯងទៅជាសត្វអភ័ព្វ ស្វែងរកចំណីអាហារបានដោយលំបាកវេទនាពន់ពេក ដោយហេតុតែខ្លួនឈ្លាសហួសពេក ។ នេះមានទំនងដូចជាមនុស្សទាំងឡាយក្នុងពួកយើងនេះ អ្នកដែលប្រកាន់ខ្លួនជាអ្នកឈ្លាសវៃហួសពេកទៅនោះ ច្រើនតែមានជោគមិនល្អ ទៅជាអភ័ព្វជាងគេវិញ ។

ធម្មតាគ្រាប់ដំណាំឬគ្រាប់ឈើមិនដែលធ្លាក់ជិតគល់ដើមឈើទេ ប៉ុន្តែត្រូវខ្យល់បក់ផាត់នាំទៅឆ្ងាយហើយដុះឬសមានពន្លកឡើងយ៉ាងណា ដូចជាគំនិតមហាសាស្ត្រាខាងចិត្តវិជ្ជា តែងទៅដុះកើតឡើងហើយមានដំឡើងដល់ទីឆ្ងាយៗ ក៏យ៉ាងនោះដែរ ។

តែងមានម្លប់មួយនៅក្រោមចង្កៀងជានិច្ច ក្នុងពេលដែលអុជបំភ្លឺសឹងមានពន្លឺចោលទៅឆ្ងាយ មើលឃើញរបស់ដែលនៅឆ្ងាយៗ នេះប្រៀបដូចជាមនុស្សទាំងឡាយ ទុកជាមានព្រះអរហន្តនៅជិតបង្កើយ ក៏មើលមិនឃើញដែរ បែរជាទៅជាប់ចិត្តស្រឡាញ់អ្នកដែលនៅឆ្ងាយវិញ (នេះត្រូវនឹងគំនិតអាចាក់ស្គុតដែលមានដំណាលក្នុងរឿងព្រេងរបស់ខ្មែរ) ។

# អំពីលោកលុយស្យេងលេវី-ព្រុហ្ល

(Lucien Lévy - Bruhl)

១៨៥៧ – ១៩៣៩

លោកនេះជាអ្នកប្រាជ្ញធំជាតិបារាំងសែស ដែលបានសិក្សាពិនិត្យអំពីដំណើរចិត្តគំនិតរបស់មនុស្សសម័យដាច់ដើម ដូចជាជនជាតិព្រៃ ពួកនេះមិនមានគំនិតគិតគូរដូចយ៉ាងប្រជាជនដែលធ្លាប់មានសេចក្ដីស៊ីវិឡៃនោះទេ ។ លោកអ្នកប្រាជ្ញយល់ថាគំនិតគិតគូររបស់មនុស្សសម័យដាច់ដើមនោះមិនមានគំនិតគិតបំបែកញែកវត្ថុធាតុផ្សេងៗ (ដូចជាយើងទេ) ដោយគេជឿថាវត្ថុធាតុទាំងអស់តែងកើតឡើងដោយឫទ្ធិអំណាចអ្វីមួយ ។ លោកមហាអ្នកប្រាជ្ញនេះបានពិសោធឲ្យឃើញពិស្ដារតាំងប្រកបទាំងការរករកឃើញរបស់លោក ហើយក្នុងខណៈដែលលោកអញ្ជើញមកកាន់ចុងបូព៌ាប្រទេសនេះ លោកបានយល់ច្បាស់ថា គំនិតយោបល់របស់លោកត្រូវពិតដូចជាលោកបានគិតមកមុននោះ ។

យើងបានដកស្រង់យកសេចក្ដីខ្លះក្នុងសៀវភៅរបស់លោកមកបង្ហាញដល់អ្នកមើលទស្សនាវដ្ដីរបស់យើងថា លោកអ្នកប្រាជ្ញនេះបានពិនិត្យរកការពិតដែលជាប់ទាក់ទងនឹងមនុស្ស និងសមាគមក្នុងចំណោមមនុស្សអស់នេះ ។ កិច្ចការរបស់លោកជាច្រើនដែលបានជួយឲ្យពួកមន្ត្រីដែល

មកនៅក្នុងចំណោមពួកពួងអាស៊ីនេះ យល់ស្គាល់ចិត្តគំនិតពួកពួង នាំឲ្យបានស្រួលដល់ការត្រួតត្រាដល់ពួកជនអស់នេះ ។

## ឫទ្ធិអំណាចមន្តអាគមដែលមាននៅនឹងគ្រឿងសស្ត្រាវុធ របស់មនុស្សសម័យជាន់ដើម

គ្រឿងអាវុធដែលខ្លាំងពូកែស័ក្តិសិទ្ធិល្អឬសមសួននោះ មិនមែនដោយមានលក្ខណៈល្អដែលមើលឃើញនឹងភ្នែក ឬដោយសារដែកនោះទេ គ្រឿងអាវុធដែលចំណាប់ល្អពូកែ ដោយផ្លូវវិជ្ជាការខាងសាសនានឹងមន្តអាគមដែលគេផ្លុំបញ្ចូលទៅក្នុងអាវុធនោះៗ ឬដោយពិធីបញ្ចុះលេខយ័ន្ត ៗ ហេតុនេះបានជាគ្រឿងអាវុធរបស់អ្នកចម្បាំង អ្នកដទៃទៀតមិនហ៊ានទៅប៉ះពាល់ទេ វៀរលែងតែអ្នកចម្បាំងប៉ុណ្ណោះ ។ ក្នុងវេលាសាន្តត្រាន្ត គេតែងយកគ្រឿងអាវុធអស់នោះទៅល្បងមើល ដើម្បីឲ្យឃើញថា មានមន្តវិជ្ជាការកាន់គ្រឿងអាវុធនោះៗហើយ ទើបគេមានសង្ឃឹមថានឹងមានជ័យជំនះ ហេតុនេះបានជាមុននឹងយកអាវុធចេញប្រើ សឹងបានល្បងមើលឃើញថាមាំពូកែមែន ។

## កំហឹងឬក្រោធ

សេចក្តីក្រេវក្រោធរបស់ពួកមនុស្សសម័យជាន់ដើមនេះ មិនមែនគេខឹងដូចជាយើងយល់នោះទេ គឺដែលយើងឃើញគេខឹងញ័រសាច់ ព្រួយ

ចិត្តជាពន្ទឹកនោះដោយគេខ្លាចទេតើ  ក្រែងយើងប្រើអំណាចសង្កត់សង្កិនពួកគេ ឬធ្វើឲ្យខូចអន្តរាយដល់ទំនៀមទម្លាប់របស់គេ ទើបយើងឃើញគេហាក់ដូចជាខឹងខ្លាំងណាស់  តែតាមពិតនោះ  ពួកនេះខ្លាចសេចក្តីរំលោភពីយើងទៅទេតើ ។ ប្រសិនបើយើងឃើញគេមិនមានមាត់ពាក្យច្រើនដូចជាយើងៗ នឹងយល់ថា  មនុស្សបែបនេះជាអ្នកខឹងច្រើនពុំបាន  ព្រោះមនុស្សពួកនេះមិនសូវចេះធ្វើឲ្យអ្នកណាខឹងទេ  ឬគ្រាន់តែធ្វើឲ្យអ្នកដទៃប្រែទឹកមុខក៏ពុំសូវមានដែរ  ព្រោះការស្គាល់កំឡាំងទឹកចិត្តរបស់គេជាមុន ឬទិស្ស័យសន្តានចិត្តរបស់មនុស្សដែលយើងត្រូវការនៅជាមួយផងនេះជាការមានប្រយោជន៍ណាស់ ។ ធម្មតាមនុស្សសម័យជាន់ដើមនោះ មិនសូវចេះនិយាយទទឹងទាស់ជាទំនាស់ដល់ចិត្តរបស់អ្នកដែលមកនិយាយជាមួយនឹងខ្លួននេះទេ ។

## ការយល់សប្តិ

សម្រាប់ចិត្តគំនិតរបស់មនុស្សសម័យជាន់ដើមនេះយល់ថា  លោកដែលមើលឃើញក្តី  លោកដែលមើលមិនឃើញក្តី  ក៏ទុកជាលោកតែមួយដូចគ្នា ។ មនុស្សជាន់ដើមអស់នេះ  មិនសូវចេះឆ្ងល់ពីរឿងយល់សប្តិទេ  គឺយល់ថាជាអំណាចមួយបណ្តាលឲ្យមានឡើងដោយឡែក  មិនបាច់សង្ស័យ  ទើបគេមិនគិតទុកថាជាអ្វីឡើយ  ទុកដូចជារបស់ដែលបានឃើញបានពិតតាមធម្មតា  ប៉ុន្តែក្នុងចំណោមជំនុំជនមនុស្សជាន់ដើមនេះ  គេនាំគ្នា

យកចិត្តទុកដាក់នឹងការយល់សប្តិ តែងនាំយករឿងយល់សប្តិនោះមកជំ-ណាលប្រាប់គ្នាទៅវិញទៅមករាល់ៗព្រឹក នឹងទាយសប្តិគ្នាតែងមានជានិច្ច ។

មនុស្សសម័យជាន់ដើមយល់ថា ការដេកលក់ស៊ប់នេះ ទុកដូចជាបងប្អូននឹងសេចក្តីស្លាប់ដែរ កាលណាយល់សប្តិក្នុងពេលដេកលក់នោះ ព្រលឹងតែងចេញទៅផុតស្រឡះពីរាងកាយ លុះព្រលឹងត្រឡប់មកវិញ ទើបរាងកាយនេះហាក់ដូចជាទើបនឹងងើបពីស្លាប់មកថ្មីៗ ។

## ការយល់សប្តិនិងអារក្សអ្នកតា

ជម្ងឺឈឺចាប់ដោយច្រើន មនុស្សជំនាន់ដើមយល់ថាមកពីពួកអារក្សអ្នកតាដែលថែរក្សាខ្លួនឲ្យទោសឬខឹងនឹងខ្លួន ដោយហេតុខ្លួនប្រព្រឹត្តជាទីទាស់ចិត្ត ឬលះបង់ចោលមិនយកចិត្តទុកដាក់នឹងអារក្សអ្នកតាខ្លួន ទើបធ្វើឲ្យកើតជម្ងឺស្លាប់ក៏មាន ឯការយល់សប្តិនោះជាគ្រឿងបង្ហាញឲ្យឃើញបំណងរបស់អារក្សអ្នកតា ហើយខ្លួនត្រូវសុំទោសបួងបន់ស្រន់តាមទំនៀមទើបបានសេចក្តីសុខ ។

## អ្នកមានមន្តវិជ្ជាក៏ធ្វើឲ្យឈឺ និងស្លាប់ក៏មានដែរ

ក្នុងចំណោមមនុស្សសម័យជាន់ដើមនេះ កាលបើមានជម្ងឺជាទម្ងន់ ឬមានមនុស្សស្លាប់នោះ គេច្រើនគិតថា ប្រសិនបើមិនមែនមកពីខ្មោច

ដីដូនដីតាធ្វើទេ មុខជាត្រូវមន្តអាគមរបស់ពួកអ្នកមានមន្តវិជ្ជាធ្វើឲ្យឈឺឬឲ្យស្លាប់ជាមិនខាន ។

## របស់ដែលកើតឬតែងនាំឲ្យអន្តរាយ

របស់ដែលគេមិនដែលស្គាល់ គេមិនទុកចិត្តសោះឡើយ ប្រសិនបើប្អូនជាសត្វឬផ្លែឈើទៅប៉ះពាល់ត្រូវវត្ថុនោះ គេក៏ប្រកាន់ថានាំឲ្យខូចខាតឬកើតសៅហ្មងឡើងមិនខាន ។

## ភ្លេង, ច្រៀងនិងរាំ

ការដែលមានកាយវាចាចិត្តរញ្ជួយយ៉ាងខ្លាំងក្នុងខណៈដែលមានបុណ្យឬពិធីអ្វីផ្សេងៗនោះ គេច្រើនចាត់ឲ្យមានលេងល្ខោន ហើយមានមនុស្សមកប្រជុំមើលល្ខោនជាច្រើនដែរ នៅវេលាដែលល្ខោនកំពុងលេង ពួកអ្នកមើលល្ខោនក៏សំដែងអាការកិរិយាទៅតាមឫកពារបស់ពួកល្ខោន គឺធ្វើជាចង្វាក់ៗ តាមភ្លេងនិងច្រៀងដូចជាពួកល្ខោន ទើបយើងមើលឃើញអាការរញ្ជួយទាំងល្ខោនទាំងអ្នកមើល ។ បើពោលតាមច្បាប់ចិត្តវិជ្ជានោះ នឹងឃើញថាការរញ្ជួយគ្រប់យ៉ាង ដំបូងគ្រាន់តែរញ្ជួយខ្លួនបន្តិចៗនឹងប្រើសូរសំឡេងប្រកបផង ដោយមិនបាច់ប្រឹងសរសៃនិងសូរសំឡេងប៉ុន្មានទេ ដល់បន្តិចទៅទើបមានអាការប្រឹងបន្តិចៗឡើង ការរញ្ជួយក៏កាន់តែខ្លាំងឡើងជាទ្វេគាត សឹងឃើញការរញ្ជួយគ្រប់សព្វសរសៃទាំងពួកល្ខោនទាំង

ពួកអ្នកមើល លាន់ឮសូរសព្ទគងរំពង ៗ មនុស្សសម័យដាន់ដើមមិនមែនគ្រាន់តែមើលល្ខោនហើយនៅស្ងៀមៗ ឬជួយប្រឹងបន្ទរបន្តិចៗប៉ុណ្ណោះទេ គឺគេចូលលេងជាមួយល្ខោនធ្វើតាមល្ខោនផង ៗ ពួកនេះយល់ថា មានអាថ៌កំបាំងអ្វីមួយនៅក្នុងស្គរ ដែលមើលមិនឃើញថាពុំត្រូវ ហើយសូរស្គរនោះមានអំណាចលាន់ឮដល់ពួកសត្វដែលមើលមិនឃើញ ទឹងខ្នែក ដូចជាវាមានអំណាចលាន់ឮមកដល់មនុស្សដូច្នោះដែរ ៗ

## អំពីការចាប់បដិសន្ធិ

ការទៅចាប់ជាតិក្នុងបរលោកនោះមិនមែនផុតអស់ត្រឹមណោះទេ កាលណាបើមានមនុស្សស្លាប់ ក៏មិនមែនស្លាប់ទៅសូន្យទេ តែងតែមកចាប់បដិសន្ធិវិញ បើចង់ត្រឡប់មកកើតក្នុងលោកនេះវិញ ៗ ក្នុងទីប្រជុំជនធំៗ តែងមានទារកមកកើតក្នុងលោកនេះ សុទ្ធតែធ្លាប់កើតក្នុងជាតិមុនៗមកហើយច្រើនជាងម្ដងឡើងទៅជាមិនខាន ៗ

## មនុស្សសម័យដាន់ដើមនិងគ្រូពេទ្យ

ពួកនេះស្អប់ខ្ពើមវិធីរក្សាពេទ្យតាមបែបទំនើបណាស់ គឺគេមិនជឿថា វិសេសដូចគ្រូពេទ្យរបស់គេ ទើបគេមិនជ្រះថ្លានឹងគ្រូពេទ្យដែលធ្វើតាមរបៀបទំនើបឡើយ ៗ

# ប្រទេសកម្ពុជា

ប្រទេសកម្ពុជាជាប្រទេសមួយ ដែលមានអាណាខេត្តនៅទិសខាងកើតនៃប្រទេសឥណ្ឌា នៅខាងត្បូងប្រទេសចិន ខាងលិចប្រទេសសៀមនឹងឥណ្ឌូស៊ីន ។ នេះជាប្រទេសមួយជាទីប្រជុំអារ្យធម៌ផ្សេងៗនឹងជនជាតិផ្សេងៗដែលចុះមកពីទិសខាងលិចរបស់ចិន ក្នុងចំណោមជាតិអស់នេះគេសំគាល់ឃើញថា:

ពួកប៉េគន ឬមនជាពួកចាស់ជាងគេ ដែលបានមកតាំងលំនៅៗក្នុងប្រទេសកម្ពុជា រៀងមកដល់ពុទ្ធសករាជ ២.២៥០ ជនជាតិនេះហើយដែលមានឥទ្ធិពលពុទ្ធសាសនា ៗ ផ្សាយចេញពេញទាំងប្រទេស ។

ពួកធានឬតៃ (ថៃ) បានរុកចុះមកក្នុងដែនលាវខាងលើនឹងដែនសៀម ជាជនជាតិមានបុទ្ធអំណាចធំមួយ ហើយទទួលយកឥទ្ធិពលពុទ្ធសាសនាមកគោរពប្រតិបត្តិដែរ ។

ពួកកម្ពុជាដែលជាជាតិចុះមកពីប្រទេសទីបេត៍ ។ ក្រោយដែលបានច្បាំងយ៉ាងម៉ឺងម៉ាត់ហើយ ទើបជនជាតិនេះទៅជាមានអំណាចនឹងជាជាតិសំខាន់ម៉ាំមួនក្នុងសម័យសព្វថ្ងៃនេះ ។ នៅមានជនជាតិដទៃទៀតជាច្រើនតាំងអំពីសម័យបុរាណកាលឡើងទៅ ក៏នៅមានជាពួកជាក្រុម (មានពួកពួនជាដើម) ក៏មាន ។

ឯព្រះពុទ្ធសាសនាដែលព្រះពុទ្ធឃោសាចារ្យបានទៅចម្លងប្រែពីលង្កាមក ហើយនាំចូលមកក្នុងប្រទេសនេះ កាលពីពុទ្ធសករាជ ៩៩៣ នៅក្នុងក្រុងប៉ាគន ។

ចម្បាំងកាំងដល់បានបំបែកប្រទេស ដែលនាំឲ្យខូចខាតស្រុកជាអនេកត្ថះទៅ ឥឡូវនេះហៅថាប្រូម នៅលើមាត់ទន្លេឥរ៉ាវតី ។ មុនដំបូងប្រទេសនេះកាន់លទ្ធិសាសនាបែបមហាយាន តែពួកមនដែលប្រកាន់លទ្ធិហីនយានបានចាត់ការផ្សាយលទ្ធិដែលព្រះបាទអសោកត្រង់ក្រុងបាដលីបុត្រកាលពី ព.ស.២៩៣ តាំងអំពីសម័យនោះមកដរាបដល់ព្រះពុទ្ធឃោសាចារ្យធ្វើដំណើរតាមសំពៅមកឡើងស្រុកថាតុន ។

ពួកភិក្ខុប្រទេសភូមា មានឈ្មោះល្បីខាងចំណេះចេះដឹងច្រើន ប្រជាជនល្បីខាងការខ្ជាប់ខ្ជួនសាសនា ពួកលោកសង្ឃយកចិត្តទុកដាក់នឹងគម្ពីរព្រះអភិធម្មជាដើម ដំបូងមានសេចក្តីចំរើនខាងអក្សរសាស្ត្រសាសនាណាស់ ដែលគេបានចារជាក់ក្នុងស្លឹករឹត រួចតមកបោះពុម្ពផ្សាយចេញជាចំនួនច្រើន មនុស្សដែលមិនចេះមើលមិនចេះសរសេរគ្មានទេ នេះជាផលចំរើននៃសាលាវត្ត ។ ក្នុងប៉ុន្មានឆ្នាំមកនេះ មានការជជែកគ្នាពីវិធីបព្វជ្ជាឧបសម្បទា គឺពួកដែលបានឧបសម្បទាពីព្រះថេរៈនៅកោះលង្កានោះមិនដឹងជាពួកនេះបានឧបសម្បទាពីនិកាយជាន់ចាស់ក្នុងស្រុកគឺមរម្មសង្ឃ

មានសាលាជាច្រើន ដែលបានជជែកតវ៉ានឹងនិកាយដទៃទៀត ។ សព្វថ្ងៃនេះ ពួកនិកាយថ្មីៗ នាំគ្នាប្រិតប្រៀនកាន់ក្រឹត្យតឹងរ៉ឹងពេក ។ ឥឡូវនេះមាននិកាយសំខាន់ៗតែពីរនិកាយទេ ហៅថា មហាគណ្ឌី ១ចុល្ល-គណ្ឌី ១ ។ ពួកនិកាយដំបូង ប្រកាន់ថាមនុស្សជាធំលើកិច្ចការរបស់ខ្លួន ឯចុល្លគណ្ឌីយល់ថាកិច្ចការទាំងអស់របស់មនុស្សតោងតែនៅក្រោមអំ-ណាចនៃកម្ម ដូច្នេះជាដើម ។

# អំពីការជាស្នាដៃរបស់ក្រសួងពុទ្ធសាសនបណ្ឌិត្យ
# នៅស្រុកខ្មែរ ស្រុកលាវ និងស្រុកកូសាំងស៊ីន

(តមកនិងចប់)

មន្ទីរនេះបានបោះពុម្ពសៀវភៅគតិលោកវៀងៗមក ហើយបានចាប់ផ្សាយសៀវភៅសរសេរសំរាប់កូនក្មេងមួយបែកមានរូបផ្សេងៗ នេះជាការទំនើបទើបនឹងកើតមុនដំបូងនៅស្រុកខ្មែរ អ្នកស្រុកក៏ចូលចិត្តសៀវភៅនេះណាស់ ព្រះរាជបណ្ណាល័យបានបោះពុម្ពបេសនីយប័ត្រមួយបែបលក់ឲ្យគល្មមនឹងធនធានខ្មែរទាំងអស់គ្នា បេសនីយប័ត្រនោះថតរូបចេនា ចំឡាក់នឹងគំនូររបស់ខ្មែរ ក្រៅពីនោះ ព្រះរាជបណ្ណាល័យបានបញ្ចូនកូនបង្ហាញពន្យល់ការផ្សេងៗ មានបកប្រែជាភាសាខ្មែរម្តងៗផង ៗ

ការមុនដំបូងដែលក្រសួងពុទ្ធសាសនបណ្ឌិត្យបានធ្វើ គឺការនាំបង្កើតកន្លែងរៀនសូត្រសម្រាប់ទាហានក្រមរក្សាស្រុកនឹងទាហានពិជ័យសង្គ្រាមនៅស្រុកខ្មែរហើយនឹងស្រុកកូសាំងស៊ីន ៗ មានរថយន្តកំសាន្តចិត្តមួយ តែងបើកទៅកំសាន្តចិត្តអ្នកស្រុកនៅក្នុងក្រុងកម្ពុជា ហើយនឹងខ្មែរនៅកូសាំងស៊ីនចំនួន ៨ ខែក្នុង ១ ឆ្នាំ ៗ ដល់រដូវប្រាំងរថយន្តនេះបើកឥតមានឈប់ឈរទេ នៅក្នុងរថយន្តនេះមានវិទ្យុមួយ ម៉ាស៊ីនច្រៀងមួយ ហើយនឹងម៉ាស៊ីនផ្ទះកុនមួយ រថយន្តនេះបើកទៅកន្លែងណាក៏បានដែរ គឺថាទៅរហូតដល់ស្រុកដែលក្រីក្រជាទីបំផុត ហើយអ្នក

ស្រុកអាចនឹងស្គាល់ ហើយឆ្លៀតយកផលប្រយោជន៍អំពីវិធីដែលទើបនឹងរកឃើញថ្មីៗបាន ។ មួយយ៉ាងទៀត នៅក្នុងរថយន្តនេះ មានកន្លែងដាក់សៀវភៅថ្មីៗសំរាប់យកទៅផ្សាយនៅវត្តឆ្ងាយៗ មានអ្នកលក់សៀវភៅម្នាក់ជាអ្នកបេះអក្សរសាស្ត្រជ្រៅជ្រះ ចាំនិយាយពន្យល់មហាជនដែលមកស្តាប់ ។ ប៉ុន្តែការដ៏ប្រសើរឧត្តមដែលក្រសួងពុទ្ធសាសនបណ្ឌិត្យសន្ទាតខំធ្វើនៅស្រុកខ្មែរ គឺការដែលរៀបចំបោះពុម្ពគម្ពីរព្រះត្រៃបិដកព្រះពុទ្ធសាសនា គម្ពីរនេះមានភាសាបាលីមួយចំហៀង មានសំរាយជាភាសាខ្មែរមួយចំហៀង ។ មានវត្តជិត ២០០០ វត្ត ហើយនឹងបណ្ដាជនជាច្រើន បានជាវគម្ពីរព្រះត្រៃបិដកនេះ គម្ពីរនេះមានចំនួនសៀវភៅជាង ១០០ក្បាល មួយក្បាលៗ មានប្រហែល ៦០០ ទំព័រ គម្ពីរនេះមិនត្រឹមតែជាឃ្លាំងសម្បត្តិចំណេះវិជ្ជាប៉ុណ្ណោះទេ គឺជាការប្រយោជន៍ដល់ជាតិជាពិតប្រាកដដោយគម្ពីរនេះជាថ្វីដៃមួយរបស់ជាតិខ្មែរធ្វើ ។ ដោយធ្វើការតាមរបៀបថ្មី មានក្រុមអ្នកប្រាជ្ញនឹងព្រះសង្ឃអ្នកប្រាជ្ញមួយពួកធ្វើការផ្ទៀងផ្ទាត់នឹងអក្សរភាសាផ្សេងៗ ដល់ ៥ ភាសា ហើយធ្វើវចនានុក្រមរើសពាក្យជាអសាធារណនាម នឹងសព្ទដែលគេប្រើក្នុងក្រសួងផ្សេងៗ ។

គម្ពីរព្រះត្រៃបិដកគេបានបោះពុម្ព ៣០ ក្បាលរួចហើយ ចំនួន ២២ ក្បាលទៀតកដការបានអនុញ្ញាតឲ្យបោះពុម្ព ឯគម្ពីរតាំងពីទី ៥៣ តទៅកំពុងរៀបចំធ្វើ ។

# នៅស្រុកលាវ

ស្នាដៃក្រសួងពុទ្ធសាសនបណ្ឌិត្យមានផលល្អជាទីបំផុត ពីព្រោះនៅស្រុកលាវខាងត្បូង តាំងពីដើមមកតែរបស់អ្វីបន្តិចក៏គ្មានដែរ ការទាំងប៉ុន្មានសុទ្ធតែពុទ្ធសាសនបណ្ឌិត្យបង្កើតឡើងទាំងអស់ ។

នៅស្រុកលាវខាងក្រោម ដែលមានស្រុកវៀងចន្ទន៍ជាទីក្រុងធំ គេបានធ្វើបញ្ជីកត់គម្ពីរដីកាទាំងអស់នៅគ្រប់វត្ត ។ នៅរោងពុម្ពស្រុកខ្មែរមានអក្សរពុម្ពលាវ តាំងពីកាលកើតពុទ្ធសាសនបណ្ឌិត្យដំបូង ហេតុដូច្នេះបានជារោងពុម្ពនេះបោះពុម្ពសៀវភៅសំរាប់សិស្សសាលាបាលីបាន ពុទ្ធសាសនបណ្ឌិត្យបានទំនុកបំរុងបង្កើតសាលាទាំងនោះ ឲ្យបានកើតឡើងទាំងអស់ គេក៏បានបើកមន្ទីរមើលសៀវភៅមួយនៅក្រុងវៀងចន្ទន៍ សាលាបេនាខាងពុទ្ធសាសនាមួយទៀតក៏បានខំជួសជុលរបង់វត្តព្រះកែវ ដែលជាវត្តមួយបានធ្វើកិច្ចដ៏សំខាន់ក្នុងពង្សាវតារស្រុកលាវខាងក្រោម ។

នៅក្នុងក្រុងហ្លួងព្រះបាង ពុទ្ធសាសនបណ្ឌិត្យបានជួយបង្កើតការសិក្សាបាលីជាថ្មី បានជួយផ្សាយរូបលាវ ជួយបង្កើតទស្សនាវដ្ដីមួយចេញរាល់ខែ ហើយជួយឲ្យបោះពុម្ពសៀវភៅច្រើនជាបាលីនិងសំរាយ ។

រាល់តែឆ្នាំ នៅក្នុងក្រុងស្រុកលាវ មានក្រុមជំនុំមួយប្រជុំគ្នាដើម្បីទទួលគិតគូរធ្វើការដែលគេឃើញថាមានផលប្រយោជន៍ខ្លះមកហើយនោះ ។

# ពង្សាវតារក្រិក

(តមក)

## វគ្គទី ៥

### និយាយពីឫទ្ធិអំណាចម៉ាសេដ្វាន ព្រះបាទហ្វីលិបនឹងព្រះបាទអាឡេក្សង់ដ្រឺ

ក្នុងរវាង ព. ស. ១៨៣ គឺរវាង ៤០ ឆ្នាំក្រោយសង្គ្រាមប៉េឡោប៉ូណែស អំណាចរបស់ស្ប៉ាតក៏សាបសូន្យថយចុះទៅ ដោយហេតុចាញ់ឧបាយកលប្រទេសប៉ែរ្ស៍ ៗ បានដណ្តើមយកអំណាចអស់ទៅជាច្រើន ៗ ចំណែកខាងអាថែនត្រឡប់ជាខំប្រឹងប្រែងកសាងកំឡាំងខាងផ្លូវសមុទ្រ បានឡើងវិញខ្លះ ៗ នៅគ្រានេះ មានអាណាចក្រ ១ ទៀតបានព្យាយាមតាំងខ្លួនឲ្យមានកំឡាំងជាត់ធំមាំមួនឡើង គឺអាណាចក្រថែប្ស៍ (Thèbes) ដោយអាស្រ័យមេទ័ពពីរនាក់ជាកំឡាំងធំ ជួយទំនុកបំរុងអាណាចក្រនេះឲ្យបានចំរើនឡើងទាំងមានមុខមាត់ស្រស់បស់ឡើងជាវេលា ១០ ឆ្នាំ ទាំងធ្វើស្រុកស្ប៉ាតដែលមិនធ្លាប់ខ្លាចអ្នកឯណាសោះ ឲ្យបែរជាទឹកកោតក្រែងអាណាចក្រថែប្ស៍នេះវិញ តែដល់អំណោះពីមេទ័ពទាំងពីរនោះទៅ សេចក្តីចំរើនរបស់ថែប្ស៍ក៏ទ្រុឌទ្រោមទៅវិញ តែនៅតាំងខ្លួនមានកំឡាំងធ្វើជាអាណាចក្រធំ ១ បាន ហើយនៅខណៈនេះ អាណាចក្រដែលមានឫទ្ធិ

របស់ក្រិកមាន ៣ គឺ ស្ប៉ាត អាថែន នឹងថែប ស្រឹងមានកំឡាំងប្រះក្រាំទឹងគ្នា មិនមានស្រុកណាមួយមានកំឡាំងល្មមមានជ័យជំនះស្រុកពីររួមគ្នាបានឡើយ ។ តមកមិនយូរប៉ុន្មាន នៅទិសខាងជើងមានអាណាចក្រ ១ ទៀតហៅថា ម៉ាសេដ្វាន (Macédoine) ខានអំណាចរុងរឿងត្រាតែទៅជារឿងសំខាន់មួយក្នុងប្រវត្តិសាស្ត្ររបស់ក្រិក ។

ម៉ាសេដ្វានជាភាគ ១ របស់ទួរគីក្នុងឩរុប ជាប្រទេសដែលមានភ្នំខ្ពស់ៗ កាលពីដើមមានសុទ្ធតែដើមឈើជាព្រៃព្រឹក្សាដេរដាស តែក្នុងសម័យនេះជាទីវាលល្វឹងជាច្រើន ជាភូមិប្រទេសមានដីជាតិល្អណាស់ អាចធ្វើការដាំដំណាំនានាបានក្នុង ១ ឆ្នាំ ៣ ដង ពួកម៉ាសេដ្វានជាជនជាតិខែងរែង មាននិស្ស័យជាអ្នកចម្បាំង អ្នកបរបាញ់ និងជាអ្នកផឹកជង ជាជនជាតិក្រិកលាយផ្សំនឹងជាតិឯទៀតៗ ជាពួកកូនកាត់ និយាយភាសាក្រិក ហើយក្សត្ររបស់ជនជាតិនេះ ជាពូជអំបូរក្រិកទាំងអស់ ។

ដោយហេតុអាថែនប្រួបរួមអំណាចខាងផ្លូវសមុទ្របានជិតអស់នោះ ឯជនពួកនេះស្ទើរតែមិនចេះធ្វើជំនួញសោះ ហើយប្រជាជនចេះតែធ្វើការដាំដំណាំ ត្រាតែដល់វេលាដែលបានធ្វើសង្គ្រាមមានជ័យជំនះមានអំ-ណាចយ៉ាងធំក្រៃលែងឡើង ទើបជនពួកនេះចេញប្រកាសខ្លួនជាជាតិក្រិកសុទ្ធឡើង ហើយទទួលគោរពរាប់អានព្រះរបស់ក្រិក ថែមទាំងបានផ្លាស់ទីក្រុងដែលនៅឆ្ងាយពីពួកក្រិកសុទ្ធនោះឲ្យកាន់តែចូលមកជិត

ស្រុកក្រិកសុទ្ធឡើងតាំងទីក្រុងថ្មីនៅស្រុកប៉ែល្លា (*Pella*) ហើយតមក ប្រជាជនម៉ាសេដ្វានក៏ក្លាយជាជាតិក្រិកសុទ្ធៗ ទៅ ។

អំពីព្រះបាទហ្វីលិបទី ២ – ក្សត្រដែលទ្រង់ធ្វើឲ្យប្រទេសម៉ាសេដ្វានមានឫទ្ធិអំណាចពិតប្រាកដឡើងនោះ គឺព្រះបាទហ្វីលិបទី ២ (*Philippe II*) ក្សត្រអង្គនេះបានទទួលការសិក្សាអំពីស្រុកក្រិក បានរៀនវិជ្ជានិយាយ វិជ្ជាធ្វើទាហាន ហើយនាំមកផងនូវវិជ្ជាការល្អៗដែលមាននៅក្នុងស្រុករបស់ទ្រង់ ថែមទាំងបានកែប្រែឲ្យកាន់តែវិសេសឡើងទៅទៀត ទ្រង់បានជួលជនជាតិដទៃមកធ្វើជាទាហាន និងបងការប្រាក់របស់ប៉ែរ្សមកធ្វើសង្គ្រាមផង ។ ព្រះបាទហ្វីលិបទ្រង់ប្រកបដោយលក្ខណៈរឹងប៉ឹងម៉ឺងម៉ាត់ និងធ្វើការគ្រប់យ៉ាងសុទ្ធតែជារបៀប និងមានបំណងយ៉ាងទៀងទាត់មិនរេរះ សេចក្ដីប៉ុនប៉ងរបស់ព្រះបាទហ្វីលិបនេះមាន ៣ ប្រការ គឺ ត្រូវការនាំអារ្យធម៌ពីខាងក្រៅចូលមកកាន់ដែនម៉ាសេដ្វាន និងព្យាយាមរៀបចំឲ្យជាតិរបស់ខ្លួនក្លាយទៅជាក្រិកសុទ្ធ និងត្រូវការឲ្យមានអំណាចផ្សាយចុះទៅដល់សមុទ្រ ១ ត្រូវការធ្វើឲ្យដែនម៉ាសេដ្វានមានអំណាចធាត់ធំជាងគេក្នុងបល្កង់ (Balkans) ១ ត្រូវការប្រមូលអាណាចក្រក្រិកទាំងអស់ឲ្យបានចងបាច់មូលគ្នា ដើម្បីលើកគ្នាទៅច្បាំងនឹងប្រទេសប៉ែរ្ស ១ ។ ព្រះបាទហ្វីលិបទ្រង់ប្រើវិធីផ្សេងៗ ទាំងកំលាំងអំណាច ទាំងឧបាយកល ទាំងមាសប្រាក់ ដើម្បីឲ្យបានសម្រេចដូចគោលមកនេះ ។

(មានតទៅទៀត)

# អនាម័យកាយ

១.ស.

ជាអ្នកប្រែនិងរៀបរៀង

(តនិងចប់)

ទឹកបស្សាវៈ, ទឹកភ្នែក, ទឹកសម្បោរ និងទឹករំអិលឯទៀតៗ— មានអាការចេញកាន់តែតិចទៅ (ហេតុនេះហើយបានជាវេលាដែលយើងងុយដេកទើបមានទឹកភ្នែកតិច ធ្វើឲ្យយើងញីភ្នែកហាមាត់ស្ងាប ការហាមាត់ស្ងាបគឺការស្រូបលោហិតឡើងមកកាន់ខួរក្បាល) ។

កាបោន (ធាតុធ្យូង) ដុតដេះក្នុងរាងកាយ— កាន់តែថយតិចទៅ ។

ជីពចរ— មានអាការកម្រើកកាន់តែយឺតទៅជាងធម្មតា ។

តាមធម្មតា ខណៈដែលខួរក្បាលឈប់សម្រាកធ្វើការ ឬឈប់ទៅនោះ ពងកាយកម្រើកដោយចេតនានោះសន្សឹមៗអស់ទៅតាមគ្នាជាលំដាប់ តែការស្តាប់ឮសូរសព្ទនោះនៅក្រោយគេបំផុត ប៉ុន្តែកាលដែលទើងភ្ញាក់ឡើងវិញនោះ ការស្តាប់ឮសូរសព្ទនោះមានមកមុនអាការឯទៀតៗទាំងអស់ ហើយអាការឯទៀតៗក៏សន្សឹមៗមានឡើងមកជាលំដាប់ ដរាបដល់កិរិយាកម្រើកដោយចេតនាមានមកក្រោយគេបង្អស់ នៅទីបំផុតយើងក៏ភ្ញាក់ពុកឡើងអំពីដំណេក ។

# ការដេកលក់ស៊ប់

ការដេកលក់ស៊ប់នោះសំដៅយកការស្ងប់ចិត្តឥតមានអាការដឹងខ្លួនសោះ ទាំងមិនមានការយល់សប្តិអាក្រក់-ល្អក្នុងខណៈនោះឡើយ ។ ឯការដេកលក់មិនស៊ប់នោះ គឺពាក់កណ្តាលលក់ពាក់កណ្តាលភ្ញាក់ រមែងមានអាការយល់សប្តិជានិច្ច ហេតុនេះ ទើបមានយល់សប្តិច្រើនក្នុងវេលាយប់ជិតជិតភ្លឺ ឬពេលជិតភ្ញាក់ពីដេក ។ ប្រសិនបើនឹងប្រើគ្រឿងវាស់ស្ទង់ការដេកស៊ប់ឬមិនស៊ប់នោះ នឹងឃើញថាការដេកលក់ស៊ប់នៅក្នុងម៉ោងទី ២ រាប់តាំងអំពីពេលដេកលក់មក តអំពីពេលនោះមកទើបសន្សឹមៗ ភ្ញាក់រលឹកឡើងវិញគ្រប់ៗ ខណៈរហូតដល់ជិតភ្លឺស្វាង ប៉ុន្តែឯក្មេងៗ ដែលមានអាយុរាង ៤ ខួប វេលាជិតភ្លឺស្វាងវៃជោដេកលក់ស៊ប់ស្រួលណាស់ ។

# អំពីហេតុដែលធ្វើឲ្យដេកលក់

គ្រូពេទ្យដែលចេះស្ទាត់ជំនាញខាងវិជ្ជានេះមានយោបល់យល់ផ្សេងៗគ្នាអំពីហេតុដែលធ្វើឲ្យដេកលក់នេះ គឺអាចារ្យខ្លះសំដែងថាព្រោះមានរបស់ជូរៗខូចៗក្នុងរាងកាយច្រើន ទើបជាហេតុធ្វើឲ្យរាងកាយទាំងខួរក្បាលមានសេចក្តីនឿយហត់ថយកំឡាំងទើបធ្វើឲ្យដេកលក់ទៅ ។ អាចារ្យខ្លះថាឲក្ស៊ែនក្នុងខ្លួនយើងកាន់តែថយអស់ទៅ ជាហេតុធ្វើឲ្យខួរក្បាលមិនបានទទួលស្រោចស្រង់ល្មមគ្រប់គ្រាន់ ទើបនាំឲ្យទន់ខ្សោយ

ថយកំឡាំងហើយក៏លក់ទៅឯង ។ អាហារខ្លះជាសរសៃប្រសាទដែលសម្ព័ន្ធបង្កាក់ទង្គាទៅវិញទៅមកញែកដាច់ចេញពីគ្នា ទើបធ្វើឲ្យដេកលក់ទៅ ។ អាហារខ្លះជាខួរក្បាលបានទទួលលោហិតតិចពេក ទើបខួរក្បាលមិនធ្វើការងារតាមមុខក្រសួង ត្រូវការឈប់សម្រាក នេះនាំឲ្យដេកលក់ទៅដែរ ។ ឯការណ៍ដែលនាំឲ្យលោហិតឡើងមកកាន់ខួរក្បាលតិចច្រើននោះ ស្រេចតែហេតុការណ៍ខាងក្រៅជាប្រមាណ ដូចជាពន្លឺ, សូរសំឡេងជាដើម អស់នេះនាំឲ្យលោហិតឡើងមកខួរក្បាលច្រើន ហេតុនេះហើយបានជាវេលាយើងដេកលក់ គេងបិទភ្នែកដើម្បីមិនឲ្យឃើញពន្លឺភ្លឺចាំងភ្នែកហើយតាំងនៅក្នុងទីស្ងាត់មិនឲ្យឮសូរសំឡេងផ្សេងៗ ។ ក្នុងកាលដែលយើងងុយដេកក្នុងខណៈដែលបរិភោគអាហាររួចហើយនោះ ដោយហេតុបំពង់លោហិតក្នុងពោះប៉ោងធំចាំទទួលអាហារ ធ្វើឲ្យលោហិតក្នុងខួរក្បាលថយតិចចុះទៅ ទើបមានអាការងុយដេក នៅវេលាក្រោយបរិភោគអាហារហើយជានិច្ច បើមានទំនងដូច្នេះគាំងប្រែថា ភ្លើងធាតុរំលាយអាហាររបស់យើងបរិបូណ៌ល្អណាស់ ។

## ការដេកយប់នឹងការដេកថ្ងៃ

យើងបានពោលមកហើយថា កាលដែលយើងនឹងដេកលក់នោះ ខួរក្បាលសន្សើមៗលះបង់ការងារជាការឈប់សម្រាក ត្រាតែការដឹងខ្លួន

អស់ទៅខ្លះឬអស់ទៅតែម្ដង ។ ដែលយើងមានអាការដូច្នេះនេះគោងតែមិនមានអារម្មណ៍ខាងក្រៅមកបៀតបៀន ដូចជាពន្លឺ ឮ សូរសម្លេង១ អស់នេះជាដើម ។ វេលាដែលប្រាសចាកសូរសំឡេងអស់នេះ មានតែវេលាយប់ទើបស្ងប់ស្ងាត់ទាំងពន្លឺទាំងសូរសំឡេងទាំង២យ៉ាង ជាហេតុនាំឲ្យខួរក្បាលមានឱកាសឈប់សម្រាកបានស្រួល គឺធ្វើឲ្យលក់ស៊ប់ស្ងួនល្អ ទើបកប់ថាជាការដេកលក់ដោយធម្មជាតិ ។ គប្បីយល់ថា បណ្ដាសព្វសត្វមានជីវិតទាំងឡាយ ធម្មតាច្រើនតែនាំឲ្យយើងរកឱកាសដេកសម្រាកតែក្នុងវេលាយប់ប៉ុណ្ណោះ ចំណែកឯវេលាថ្ងៃច្រើនតែមានគ្រឿងនាំឲ្យរញ្ជួយដល់សរសៃប្រសាទដោយជុំវិញ ដូចជាពន្លឺ សូរសំឡេងនឹងសូរគគ្រាំងជាដើម ដែលធ្វើឲ្យខួរក្បាលម្នាប់ពុំបាន ទុកជាព្យាយាមម្នាប់ឬដេកទៅទាំងបង្ខំ ក៏គង់តែមិនលក់ស៊ប់ស្ងួនតាមប្រក្រតីបាន ហេតុនេះការដេកក្នុងវេលាយប់ទើបលក់ស៊ប់ស្ងួនស្រួលជាងវេលាថ្ងៃច្រើនណាស់ ។ ទើបសរុបសេចក្ដីដូច្នេះ

## ការដេកត្រូវការ

១ ឲ្យមានរបស់ផ្សេងៗផ្អែមៗច្រើន ដោយវិធីហាត់ប្រាណធ្វើឲ្យចេញញើស ជាហេតុធ្វើឲ្យខួរក្បាលនឿយអស់កំឡាំងចង់ដេកសម្រាកទើបដេកលក់បានងាយស្រួល ។

២) ធ្វើអុកស៊ីសែនឲ្យអស់ទៅ គឺថាធ្វើការងារដោយប្រើខួរក្បាល តែល្មមប្រមាណកុំឲ្យច្រើនហួសពេក ។

៣) ធ្វើឲ្យសរសៃប្រសាទរួញ ដោយវិធីស្ងប់ស្ងាត់ទឹងទឹត ។

៤) ធ្វើឲ្យលោហិតឡើងមកកាន់ខួរក្បាលតិច ដោយវិធីបញ្ចោត លោហិតឲ្យចុះមកកាន់កាយច្រើន ឬការពារគ្រឿងបៀតបៀនផ្សេងៗ ដែលធ្វើលោហិតឲ្យឡើងមកកាន់ខួរក្បាល ដូចជាផឹកសុរា, ទឹកតែ, កាហ្វេជាដើម ។

## ការដេកមិនលក់

បានពោលខាងដើមរួចហើយថា ការដែលយើងដេកលក់នោះគោង អាស្រ័យហេតុផ្សេងៗ ហេតុដែលសំខាន់គឺលោហិតដែលឡើងមកកាន់ខួរក្បាលតិចចុះទៅ ទើបធ្វើឲ្យខួរក្បាលឈប់សម្រាកធ្វើការជាបណ្ដោះអាសន្នសិន ។ ឯការដេកមិនលក់នោះ មានហេតុផ្សេងដោយឡែកពីនេះ គឺ (ក) ហេតុខាងក្រៅ (ខ) ហេតុខាងក្នុង (គ) ហេតុដែលមិនទាន់ដឹងប្រាកដ ។

## (ក) ហេតុខាងក្រៅ

១) កើតពីជម្ងឺនិងរោគ — ដូចជាឈឺចាប់ត្រង់មុខរបួសឬត្រូវរងា កំដៅក្នុងខ្លួនឡើងខ្លាំង រោគក្អក រោគស្ទួតមានរោគរបេងជាដើម ការដកដង្ហើមមិនស្រួលបណ្ដាលមកពីបេះដូងពិការ ។

២) គ្រឿងបៀតបៀនផ្សេងៗ — ដូចជាពន្លឺទឹងសូរសំឡេងជាដើមដូចពោលរួចមកហើយខាងដើម ហេតុនេះការដេកថ្ងៃដែលជាវេលាគេធ្វើការងារជាហេតុធ្វើឲ្យមានសូរសំឡេងក្ដុងក្ដាំងមកបៀតបៀនយើងជានិច្ច ។

## ១) ហេតុខាងក្នុង

១) សេចក្ដីភិតភ័យ — កើតឡើងដោយហេតុឯណាមួយដូចជាភ្លើងឆេះ ឬដំណើរអាក្រក់ផ្សេងៗ ។

២) ការប្រើគំនិត — បណ្ដាលមកពីធ្វើការងារ ប្រើសរសៃប្រសាទលើសកំណត់ ដូចជាពួកគ្រូ, ពេទ្យ, ចៅក្រម, អ្នករៀន ឬកើតមកពីសេចក្ដីតូចចិត្តទោមនស្សផ្សេងៗ ។

៣) គ្រឿងពុលផ្សេងៗ — ដូចកញ្ឆា, បារី, អាភៀនទឹកស្រាមេរ័យ ផឹកកាហ្វេជិតពេលដេក ឬពេកទល់លាមកជាដើម ក៏ជាហេតុធ្វើឲ្យដេកមិនលក់ដែរ ។

៤) សេចក្ដីចាស់ជរា — មកអំពីតួលោហិតឡើងលើច្រើន ទើបធ្វើឲ្យលោ-ហិតដក់នៅក្នុងខួរក្បាលច្រើនហួសកំណត់ ។

## គ) ហេតុដែលមិនទាន់ដឹង

គឺកើតមកពីការប្រែប្រួលក្នុងខួរក្បាលនុ៎ះឯង មិនមែនហេតុដទៃទេ នៅសុខៗ ស្រាប់តែដេកមិនលក់ ហើយយូរៗ ទៅក្លាយទៅជាមនុស្ស

ឆ្កួតខូបបរិតក៏សឹងមាន រោគអស់នេះច្រើនកើតដល់ស្ត្រីចិត្តទន់ច្រើនខ្លាច មានភ័យភ្ញាក់ច្រើន ឬកើតដល់មនុស្សប្រុសដែលមានមុខក្រសួងទទួលខុស-ត្រូវច្រើន តាមដែលពោលមកនេះនឹងឃើញថា ការដេកមិនលក់មានហេតុច្រើនប្រការណាស់ ហើយបើយើងត្រូវការដេកឲ្យលក់ស៊ប់ស្ងួន តោងតែកំចាត់ដើមហេតុនោះចេញ ចំណែកដែលយើងល្មមកែដោយខ្លួនយើងបានក៏គួរកែខៃដោយខ្លួនឯងទៅ ចំណែកដែលមិនមែនជាកំហុសរបស់យើងដូចជាបណ្តាលមកពីគេ គួរប្រគល់ឲ្យគ្រូពេទ្យចាត់ចែងកែខៃតទៅ ។ .

ចប់អនាមយកថា ដោយសង្ខេកតែប៉ុណ្ណោះ